ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

------

សំណុំរឿង ព្រហ្មទណ្ឌ

លេខ : ១៥

ចុះថ្ងៃទី២៦ - ២ - ៩៩

សាលដីកា

------

លេខ : ៤០

ចុះថ្ងៃទី០១ - ៨ - ២០០១

តាងនាមប្រជារាស្ត្រខ្មែរ

តុ លា កា រ កំ ពូ ល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០០១ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១- ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រមរបាយការណ៍

៣- លោក ទេវ៉ុល មួន ចៅក្រម

៤- លោក សោម សិរីវឌ្ឍ ចៅក្រម

៥- លោក យស់ ហួរខឿន ចៅក្រម

លោក ឃាង ស្រ៊ុន ក្រឡាបញ្ជី

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនឡេង អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ២១២ ចុះថ្ងៃទី៣០ - ៩ - ៩៨ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ១៥ ចុះថ្ងៃទី២៦ - ២ - ៩៩ របស់តុលាការកំពូល ។

ពីបទ : ក្លែងលិខិតសាធារណៈ ប្រព្រឹត្តនៅភូមិត្នោតតូច ឃុំអង្គរមាស ស្រុកដងទង់ ខេត្តកំពត កាលពីថ្ងៃទី៣០ - ១២ - ៩០ បទល្មើសដែលមានចែងតាមមាត្រា៤៩ នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល ។

- ជនជាប់ចោទឈ្មោះជុំ កេង "ចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ៥០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិភ្នំពេញ ឃុំឃ្លាយ ស្រុកបន្ទាយមាស ខេត្តកំពត របររកស៊ីធ្វើស្រែ ទីលំនៅសព្វថ្ងៃនៅភូមិត្នោតតូច ឃុំអង្គរមាស ស្រុកដងទង់ ខេត្តកំពត ឪពុកឈ្មោះជុំ ជិន "ស" ម្តាយឈ្មោះផុង គាត់ "ស" ប្តីឈ្មោះ អ៊ឹង ធី មានកូន៦នាក់ ទោសពីមុនគ្មាន ។

- ជនជាប់ចោទឈ្មោះអ៊ឹង ធី "ចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៥៩ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រៃក្រាំង ឃុំស្រែជា ស្រុកកំពង់ត្រាច ខេត្តកំពត របររកស៊ីធ្វើស្រែ ទីលំនៅសព្វថ្ងៃ ភូមិត្នោតតូច ឃុំអង្គរមាស ស្រុកដងទង់ ខេត្តកំពត ឪពុកឈ្មោះអ៊ឹង ឃាង "ស" ម្តាយឈ្មោះទ្វាយ-ញៀត "ស" ប្រពន្ធឈ្មោះជុំ កេង មានកូន៦នាក់ ទោសពីមុនគ្មាន ។

មេធាវី គ្មាន

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះសង ស៊ឹម ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ - ឃុំឫស្សីស្រុកាំង ស្រុកមោងឫស្សី ខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃនៅភូមិត្នោតតូច ស្រុកអង្គរមាស -

ស្រុកដងទង់ ខេត្តកំពត ឪពុកឈ្មោះស៊ុម សង "ស" ម្តាយឈ្មោះង៉ែត ម៉ុំ "រ" ប្រពន្ធឈ្មោះ - ភោគ សំបន មានកូន ៦នាក់ ។

មេធាវី គ្មាន

- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ "ម្ចាស់បណ្តឹងសាទុក្ខ" លេខ៤៧ ចុះថ្ងៃទី - ២៦ ខែតុលា ឆ្នាំ១៩៩៨ ។

- តាមពាក្យបណ្តឹងចុះថ្ងៃទី២២ - ០១ - ៩៧ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះសង ស៊ុម បញ្ជាក់ថា កាលពីឆ្នាំ១៩៩០ ខ្លួននៅធ្វើចំការ ហើយត្រូវរបួសដោយមានជីវភាពខ្វះខាត ខ្លួនបានអោយប្រពន្ធខ្លួនយកដីស្រែទំហំ៤០អា ទៅបញ្ចាំអោយឈ្មោះជុំ កេង ដែលមានលោកវ៉ា នឹម ជាមេក្រុមចាស់ជួយសរសេរលិខិតផង ។ ពេលនោះឈ្មោះជុំ កេង ថាកុំអោយសរសេរដាក់បញ្ចាំសរសេរថាលក់ទៅ ប៉ុន្តែឈ្មោះវ៉ា នឹម មិនព្រមហើយគាត់បានបន្ថែមទៀតថា បើគេមកលោះថ្ងៃណា ឆ្នាំណាក៏លោះទៅវិញចុះ ។ ស្រាប់តែដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ខ្លួនបានទៅរកលិខិតពីឈ្មោះវ៉ានឹម ដើម្បីមកលោះដីវិញ គាត់ថាដុតចោលអស់ហើយ ។ តែឡូវនេះបែរជាឈ្មោះជុំ កេង មានលិខិតក្លែងក្លាយពីណាមកដាក់ថា ប្រពន្ធខ្លួនបានលក់ដីអោយទៅគាត់ ហើយគាត់មិនទទួលស្គាល់ថាដីនេះជាដីបញ្ចាំទេ ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការខេត្តកំពតថា : បានសំរេចចោទប្រកាន់ឈ្មោះ អ៊ុង ធី ភេទប្រុស អាយុ៥៩ឆ្នាំ និងឈ្មោះជុំ កេង ភេទស្រី អាយុ ៥៦ឆ្នាំ ពីបទ ក្លែងលិខិតសាធារណៈ ប្រព្រឹត្តនៅភូមិស្នោរតូច ឃុំអង្គរមាស ស្រុកដងទង់ ខេត្តកំពត កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩០ តាមមាត្រា៤៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញដីកាលើកលែងចោទប្រកាន់លេខ២៨៦ ចុះថ្ងៃទី២០ - ៨ - ៩៧ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកំពត ដែលបានសំរេចថា :

លើកលែងចោទប្រកាន់ឈ្មោះ

- អ៊ុង ធី ភេទប្រុស អាយុ៥៩ឆ្នាំ ជាតិខ្មែរ
- ជុំ កេង ភេទស្រី អាយុ៥៦ឆ្នាំ ជាតិខ្មែរ

ទីលំនៅសព្វថ្ងៃ ភូមិស្នោរតូច ឃុំអង្គរមាស ស្រុកដងទង់ ខេត្តកំពត ជាប់ចោទពីបទក្លែងលិខិតសាធារណៈ ប្រព្រឹត្តនៅភូមិស្នោរតូច ឃុំអង្គរមាស ស្រុកដងទង់ ខេត្តកំពត កាលពីថ្ងៃទី ៣០ - ១២ - ៩០ និងសំរេចអោយដោះលែងឈ្មោះនេះចេញពីមន្ទីរឃុំឃាំងជាបន្ទាន់បើជននោះមិនត្រូវឃុំខ្លួនពីបទល្មើសអ្វីផ្សេងទៀតទេ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ២៤ ចុះថ្ងៃទី២០ - ៨ - ៩៧ របស់លោកព្រះរាជអាជ្ញាអមតុលាការខេត្តកំពត ដែលប្តឹងតវ៉ាពីដីកាសំរេចលេខ២៨៦ ចុះថ្ងៃទី២០ - ៨ - ៩៧ ត្រង់ចំណុច :

- ស៊ើបអង្កេតមិនទាន់មូល
- មិនបានសួរចម្លើយជនរងគ្រោះ
- មិនបានធ្វើកោសល្យវិច័យលើឯកសារក្លែង

- ការដកពាក្យបណ្ដឹងរបស់ជនរងគ្រោះពុំអាចរំលត់បណ្ដឹងអាជ្ញាបានទេ ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ថា ៖

១ - ទទួលបណ្ដឹងឧទ្ធរណ៍លេខ០៧៩ ចុះថ្ងៃទី១៨ - ៥ - ៩៧ របស់ព្រះរាជអាជ្ញាតុលាការខេត្តកំពត ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២ - បដិសេធដីកាលើកលែងចោទប្រកាន់ លេខ២៨៦ និង២៨៧ ចុះថ្ងៃទី២០ - ៨ - ៩៧ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកំពតចោលជាអសារបង់ ។

៣ - បង្គិលសំណុំរឿងទៅតុលាការខេត្តកំពត ដើម្បីចាត់ការបន្ត តាមនីតិវិធីឡើងវិញ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១២១២ ចុះថ្ងៃទី៣០ - ៥ - ៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច ៖

១ - ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២០ - ៨ - ៩៧ របស់ព្រះរាជអាជ្ញា អមតុលាការខេត្តកំពត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ បដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២ - តម្កល់ដីកាលើកលែងចោទប្រកាន់លេខ២៨៦និង២៨៧ ចុះថ្ងៃទី២០ - ៨ - ៩៧ របស់ចៅក្រមស៊ើបអង្កេត តុលាការខេត្តកំពត ទុកជាបានការដដែល ។

៣ - សាលដីកានេះជំនុំជំរះនិងប្រកាសសាធារណៈកំបាំងមុខ ជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវប្ដឹងទាស់ និងសាទុក្ខតាមកំណត់ច្បាប់ ។

- បានឃើញបណ្ដឹងសាទុក្ខលេខ០៤៧ ចុះថ្ងៃទី២៦ - ១០ - ៩៨ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្ដឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ១២១២ ចុះថ្ងៃទី៣០ - ៥ - ៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី១៨ - ១២ - ៩៨ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានឃើញសារណាតបចុះថ្ងៃទី១៧ - ៥ - ៩៩ របស់ឈ្មោះអ៊ុង ធី និងនាងជុំ កេង ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូល ថា ៖ ការស៊ើបអង្កេតមិនទាន់មូល មិនបានធ្វើកោសល្យវិច័យលើឯកសារក្លែង ការដកពាក្យបណ្ដឹងរបស់ជនរង-គ្រោះពុំអាចបញ្ឈប់បណ្ដឹងអាជ្ញាបានទេ ។ សាលដីការបស់សាលាឧទ្ធរណ៍មានការខុសឆ្គងទាំងទំរង់ នឹងគតិច្បាប់ ។ បង្គិលសំណុំរឿងទៅតុលាការខេត្តកំពត ដើម្បីចាត់ការបន្តតាមនីតិវិធី ។

- បានស្ដាប់សារណារបស់ឯកឧត្ដមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

- បានស្ដាប់សារណាតបរបស់ជនជាប់ចោទឈ្មោះជុំ កេង និង អ៊ុង ធី

- បានស្ដាប់សេចក្ដីសន្និដ្ឋានបន្ថែមនាពេលសវនាការរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា ៖ សូមរក្សាការសន្និដ្ឋានរបស់ខ្លួនទៅដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍ សារណា របស់ជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៤៧ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៨ របស់ឯកឧត្តម អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថាការដែលចៅក្រមស៊ើបអង្កេតតុលាការខេត្តកំពត ក៏ដូចសាលាឧទ្ធរណ៍ដែរ ដែលសំរេចលើកលែងចោទប្រកាន់លើឈ្មោះជុំ កេង និងឈ្មោះអ៊ឹង ធី ដោយអាងហេតុថា ជនរងគ្រោះបានទទួលថាខ្លួនបានផ្តិតមេដៃលើលិខិតដែលចោទថាក្លែងនោះមែន និងដោយអាងហេតុថា បទល្មើសក្លែងនេះធ្វើឡើងមុនច្បាប់ព្រហ្មទណ្ឌអន្តរកាលចូលជាធរមាននោះ នោះជាការភាន់ច្រឡំ ពីព្រោះថា: - រឿងនេះជាបទអាជ្ញាដោយការដកពាក្យបណ្តឹងរបស់ជនរងគ្រោះពុំអាចបញ្ចប់បណ្តឹងអាជ្ញាឡើយ ហើយចម្លើយទទួលស្គាល់របស់ជនរងគ្រោះពុំអាចចាត់ទុកជាភស្តុតាងដោះបន្ទុកបានទេ។

- ថ្វីបើការក្លែងលិខិតនេះធ្វើឡើងមុនការចូលជាធរមាន នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ក៏ពិតមែន ប៉ុន្តែលិខិតនេះត្រូវបានប្រើប្រាស់រហូតដល់ច្បាប់ព្រហ្មទណ្ឌអន្តរកាលចូលជាធរមានរួចហើយ ។

- យល់ឃើញថា ក្នុងការសំរេចលើកលែងចោទប្រកាន់ចៅក្រមស៊ើបអង្កេតពុំបានបំពេញបែបបទតាមការកំណត់នៃនីតិវិធីឡើយ ។

- យល់ឃើញថា ក្នុងការស៊ើបអង្កេតពីបទក្លែង ចៅក្រមស៊ើបអង្កេតពុំទាន់បានធ្វើការស៊ើបអង្កេតមូលនៅឡើយទេ គប្បីតុលាការកំពូលបង្វិលសំណុំរឿងនេះទៅតុលាការសាមីដើម្បីធ្វើការស៊ើបអង្កេតបន្ថែមអោយបានច្បាស់លាស់ ។

- យល់ឃើញថា ទាំងជនជាប់ចោទ ទាំងដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ២១២ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែល សំរេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី កំបាំងមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

១- ទទួលបណ្តឹងសាទុក្ខលេខ ៤៧ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៨ របស់ឯកឧត្តម អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២ - ទុកជាមោឃៈដីកាលើកលែងចោទប្រកាន់លេខ១២៨៦ និងលេខ១២៨៧ ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ១៩៩៧ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកំពត និងសាលដីកាព្រហ្មទណ្ឌលេខ ២១២ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣ - បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ១៥ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់ តុលាការកំពូល ទៅ តុលាការខេត្តកំពតដើម្បីចាត់ការបន្ត ។

៤ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០០១ ។